**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និងកាមរោគ
លេខ៖ ០៦៩៥ មជអសក

ថ្ងៃ ពុធ ៦ រោច ខែ អស្សុជ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០២០

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

**គោរពជូន**

**លោក-លោកស្រី ប្រធានមន្ទីរពេទ្យ** ...............................

**កម្មវត្ថុ៖** ការកែប្រែនិយមន័យនៃករណីលះបង់ការព្យាបាល(LTFU = Lost To Follow Up) សម្រាប់អ្នកជំងឺអេដស៍នៅសេវាពិនិត្យ និងព្យាបាលជំងឺអេដស៍។

**យោង៖** គោលការណ៍ណែនាំអំពីព័ត៌មានជាយុទ្ធសាស្ត្ររបស់អង្គការសុខភាពពិភពលោក "Consolidated Strategic Information Guidelines, Driving Impact through programme monitoring and management (HIV Strategic Information for Impact) April 2020" (https://apps.who.int/iris/rest/bitstreams/1274308/retrieve).(ទំព័រទី ១០៣ កថាខណ្ឌ ខាងក្រោម)

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក-លោកស្រីប្រធានមន្ទីរពេទ្យមេត្តាជ្រាបថា មជ្ឈមណ្ឌលជាតិសូមធ្វើការកែប្រែនិយមន័យនៃការលះបង់ការព្យាបាល (Lost To Follow Up) សម្រាប់អ្នកជំងឺអេដស៍នៃសេវា ART ដើម្បីឱ្យស្របតាមការណែនាំរបស់អង្គការសុខភាពពិភពលោកដូចខាងក្រោមនេះ៖

គ្រប់អ្នកជំងឺអេដស៍ដែលមកទទួលការព្យាបាលយឺតលើសពី ***២៨ថ្ងៃ បន្ទាប់ពីថ្ងៃណាត់ជួបចុងក្រោយ*** **ត្រូវចាត់ទុកថាជាករណី "លះបង់ការព្យាបាល"** (LTFU) ។

និយមន័យថ្មីនៃករណីលះបង់ការព្យាបាល(LTFU) នេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ខាងមុខនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីប្រធានមន្ទីរពេទ្យ មេត្តាជួយសម្រួលដល់ការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព ដោយក្តីអនុគ្រោះ។

សូមលោក-លោកស្រីប្រធានមន្ទីរពេទ្យ មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**វេជ្ជ.លី-ពេញ ស៊ុន**

**ចម្លងជូន:**

- សេវាពិនិត្យ និងព្យាបាលជំងឺអេដស៍
  "ដើម្បីសហការអនុវត្ត"

អាគារលេខ ២៤៥ H ផ្លូវជាតិលេខ ៦អា ភូមិកៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ អ៊ីម៉ែល: info@nchads.org, Website: www.nchads.org